ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ✓ មស.

សារលិខិតជូនពរ

សូមគោរពជូន

សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា

សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់

ក្នុងឱកាសចម្រើនជន្មាយុគម្រប់ ៦៧ឆ្នាំ ឈានចូល ៦៨ឆ្នាំ របស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា** នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ នេះ យើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមប្រសិទ្ធពរជ័យ សិរីសួស្តី បវរមហាប្រសើរ ជូនចំពោះ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** សូមសមប្រកបដោយសុខភាពល្អបរិបូរណ៌ កាយពលមាំមួន ប្រាជ្ញាវាងវៃ និងជន្មាយុយឺនយូរ។

យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវការកោតសរសើរដោយស្មោះចំពោះការដឹកនាំរបស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ដែលជានិច្চកាលបានពុះពារលះបង់ប្រឹងប្រែងក្នុងការជួយដោះស្រាយទុក្ខលំបាករបស់ប្រជាជនគ្រប់ពេលវេលា បង្ហាញយ៉ាងប្រត្យក្សនូវគំរូវីរៈភាព ជាស្ត្រីឆ្នើមមួយរូបរបស់ប្រទេសជាតិ ជាភរិយា និងជាមាតាដ៏ប្រសើរឧត្តម។

ជាថ្មីម្តងទៀត យើងខ្ញុំទាំងអស់គ្នាសូមអនុញ្ញាតគោរពជូនពរ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន និងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី** ជាទីស្រលាញ់របស់ **សម្តេច** សូមបានប្រកបដោយពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅ និងខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ។

ថ្ងៃ ព្រហស្បតិ៍ ៤ កើត ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ២០២១

រដ្ឋមន្ត្រី

ង្វៀ-សុខា